J Trust Royal Bank

## ការណែនាំឯកសារយោងរហ័ស

# សេវាកម្មធនាគារតាមអ៊ីនធើណិត ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

ប្រតិបត្តិការធនាគារដោយសាមញ្ញ និង ងាយស្រួលនៅលើម្រាមដៃលោកអ្នក
គ្រប់ពេលវេលា គ្រប់ទីកន្លែង

## ការចូលដំណើរការលើកដំបូង (ការចុះឈ្មោះដោយខ្លួនឯង)



2019 All rights reserved

# ការចូលដំណើរការលើកដំបូង (ការចុះឈ្មោះដោយខ្លួនឯង)

J Trust Royal Bank

## ទម្រង់សេវាកម្មធនាគារតាមអ៊ីនធើណិត

**ជំហានទី១.** មុនពេលលោកអ្នកចូលដំណើរការសេវាកម្មធនាគារតាមអ៊ីនធើណិតលើកដំបូង លោកអ្នកត្រូវបំពេញការចុះឈ្មោះដោយខ្លួនឯង

- ចូលទៅកាន់គេហទំព័រសេវាកម្មធនាគារតាមអ៊ីនធើណិតរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់។
- ចុច 'ការចុះឈ្មោះដោយខ្លួនឯង' ។




## ទម្រង់សេវាកម្មធនាគារតាមទូរសព្ទ

**ជំហានទី១.** នៅពេលលោកអ្នកចូលដំណើរការតាមទម្រង់សេវាធនាគារតាមទូរសព្ទ លោកអ្នកអាចនឹងធ្វើតាមជំហានខាងក្រោមដើម្បីចូលដំណើរការ។

- បើកកម្មវិធី
- បញ្ចូលឈ្មោះអ្នកប្រើ ... សម្ងាត់
- ចុច

**ទម្រង់សេវាកម្មធនាគារតាមទូរសព្ទ នឹងមកដល់ឆាប់ៗនេះ**



## បញ្ចូលលេខទូរសព្ទចល័តដែលត្រឹមត្រូវ

**ជំហានទី២.** បន្ទាប់មកលោកអ្នកត្រូវបញ្ចូលលេខទូរសព្ទចល័តដែលលោកអ្នកបានចុះឈ្មោះជាមួយធនាគារ។

ផ្លាស់ប្តូរលំនាំដើម KH(+855) ប្រសិនបើត្រូវការ។




## បញ្ចូលលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ (OTP)

**ជំហានទី៣.** នៅពេលបញ្ចូលលេខទូរសព្ទចល័តរបស់លោកអ្នក លេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ (OTP) នឹងផ្ញើទៅកាន់លេខទូរសព្ទចល័តដែលលោកអ្នកបានចុះឈ្មោះ។

បញ្ចូលលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ (OTP) ៦ខ្ទង់ បន្ទាប់មកចុចសញ្ញាព្រួញពណ៌លឿង។

ចុចកន្លែង 'ផ្ញើលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ (OTP) សារជាថ្មី' ដើម្បីផ្ញើលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះថ្មីទៅកាន់លេខទូរសព្ទចល័តរបស់លោកអ្នក។




## ផ្ទាំងផ្ទៀងផ្ទាត់

**ជំហានទី៤.** នៅពេលបញ្ចូលលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ (OTP) លោកអ្នកនឹងឃើញការផ្ទៀងផ្ទាត់បង្ហាញ។

លោកអ្នកនឹងទៅដល់ផ្ទាំងបន្ទាប់ដោយស្វ័យប្រវត្តិ។



# បញ្ចូលអត្តសញ្ញាណអតិថិជន និង ថ្ងៃខែឆ្នាំកំណើត

**ជំហានទី៥.** ផ្ទាំងភាពលម្អិតអត្តសញ្ញាណអតិថិជននឹងបង្ហាញ។

- បញ្ចូល 'លេខអត្តសញ្ញាណអតិថិជន' របស់លោកអ្នក – នេះគឺជាលេខអត្តសញ្ញាណអតិថិជនរបស់លោកអ្នកជាមួយធនាគារ។
- បញ្ចូល 'ថ្ងៃខែឆ្នាំកំណើត' របស់លោកអ្នក។
- ចុចសញ្ញាព្រួញពណ៌លឿងដើម្បីបញ្ជូន។

**សម្គាល់**: ប្រសិនបើលោកអ្នកបានមិនដឹងពី 'អត្តសញ្ញាណអតិថិជន' របស់លោកអ្នក សូមអញ្ជើញទៅកាន់សាខាដែលនៅជិត ឬ ទាក់ទងមកផ្នែកសេវាកម្មបំរើអតិថិជនរបស់យើងខ្ញុំ២៤ម៉ោងតាមរយៈទូរសព្ទលេខ០២៣ ៩៩៩ ០០០។




# ផ្ទាំងបញ្ជាក់

**ជំហានទី៦.** ផ្ទាំងបញ្ជាក់ជាមួយព័ត៌មានផ្ទាល់ខ្លួននឹងបង្ហាញ។

- ចុចសញ្ញាព្រួញពណ៌លឿងដើម្បីបញ្ជូន

**សម្គាល់**: សូមត្រួតពិនិត្យបច្ចុប្បន្នភាពព័ត៌មានលោកអ្នក។ សូមអញ្ជើញទៅកាន់សាខាដែលនៅជិត ឬ ទាក់ទងមកផ្នែកសេវាកម្មបំរើអតិថិជនរបស់យើងខ្ញុំ២៤ម៉ោងតាមរយៈទូរសព្ទលេខ០២៣ ៩៩៩ ០០០ ដើម្បីសម្គាល់លោកអ្នក និង កែតម្រូវព័ត៌មានផ្ទាល់ខ្លួនលោកអ្នក។




# ឈ្មោះអ្នកប្រើប្រាស់ និង លេខសម្ងាត់

**ជំហានទី៧.** បន្ទាប់ពីការបញ្ជាក់ ឈ្មោះអ្នកប្រើប្រាស់ថ្មីនឹងបង្ហាញដែលជាលេខ ៨ ខ្ទង់របស់លោកអ្នក។

- បន្ទាប់មកបញ្ចូលលេខសម្ងាត់ថ្មី និង បញ្ចូលលេខសម្ងាត់នេះម្តងទៀតដើម្បីបញ្ជាក់។
- ចុចសញ្ញាព្រួញពណ៌លឿងដើម្បីដំណើរការ។

**សម្គាល់**: សូមកត់ត្រាឈ្មោះអ្នកប្រើប្រាស់ថ្មីរបស់លោកអ្នក (លេខកូដ ៨ ខ្ទង់) និង លេខសម្ងាត់ថ្មីដោយសារ លោកអ្នកនឹងត្រូវការឈ្មោះអ្នកប្រើប្រាស់និងលេខសម្ងាត់សម្រាប់ចូលដំណើរនៅពេលក្រោយ។



# ការចូលដំណើរការលើកដំបូង (ការចុះឈ្មោះដោយខ្លួនឯង)

J Trust Royal Bank

## ខ និង លក្ខខណ្ឌ

**ជំហានទី៨.** លោកអ្នកនឹងទៅកាន់ទំព័រ ខ និង លក្ខខណ្ឌ។

- សូមអាន ខ និង លក្ខខណ្ឌ បន្ទាប់មកមើលចុះក្រោម។
- ចុច ‘យល់ព្រម’ នឹង ខ និង លក្ខខណ្ឌ
- ប្រសិនបើលោកអ្នកចុច ‘លុបចោល’ លោកអ្នកនឹងទៅត្រលប់ទៅដល់ទំព័រដើមចូលដំណើរការ។ ដោយមិនបានយល់ព្រម នឹង ខ និង លក្ខខណ្ឌ លោកអ្នកមិនអាចចូលទំព័រដើមសេវាកម្មធនាគារតាមអ៊ីនធើណិត ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់បានទេ។



# ការចូលដំណើរការលើកដំបូង (ការចុះឈ្មោះដោយខ្លួនឯង)

J Trust Royal Bank

## ទំព័រដើមសេវាកម្មធនាគារតាមអ៊ីនធើណិត

ជំហានទី៨. ឥឡូវលោកអ្នកនឹងមកដល់ទំព័រដើមសេវាកម្មធនាគារតាមអ៊ីនធើណិត។




## ទំព័រដើមសេវាកម្មធនាគារតាមទូរសព្ទ

ជំហានទី៨. ឥឡូវលោកអ្នកនឹងមកដល់ទំព័រដើមសេវាកម្ម ធនាគារតាមទូរសព្ទ។

**ទម្រង់សេវាកម្មធនាគារតាមទូរសព្ទ នឹងមកដល់ឆាប់ៗនេះ**

